# ជំនួយស្មារតី
## អំពី
## "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តឧត្តរមានជ័យ"

-សូមក្រាបថ្វាយបង្គំសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីទាំងពីរគណៈ និងព្រះថេរានុថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ!

-សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជាជាទីគោរពដ៏ខ្ពង់ខ្ពស់!

-សូមគោរពសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!

-ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកសារព័ត៌មាន និងបងប្អូនប្រជាពលរដ្ឋទាំងអស់ជាទីមេត្រី និងជាទីស្នេហា!

ថ្ងៃនេះ ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្តឧត្តរមានជ័យ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាមានក្តីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលដែលបានរៀបចំសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តឧត្តរមានជ័យ" និងសូមថ្លែងអំណរគុណបងប្អូនអ្នកសារព័ត៌មានដែលមានវត្តមាននៅទីនេះ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋដែលកំពុងតាមដានការផ្សាយសន្និសីទសារព័ត៌មាននាឱកាសនេះ។

នេះជាលើកទីពីរ ដែលខ្ញុំមានកិត្តិយសបានមកធ្វើបទបង្ហាញពីវឌ្ឍនភាពរីកចម្រើនរបស់ខេត្តឧត្តរមានជ័យក្នុងរយៈកាល៥ឆ្នាំកន្លងមក តាមរយៈសន្និសីទសារព័ត៌មាន ដែលរៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល នៅអគារទីស្តីការគណៈរដ្ឋមន្ត្រី។

ដោយអនុវត្តតាមគោលនយោបាយដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អគ្គមគ្គុទេសន៍ដ៏ឆ្នើម កន្លងមកនេះដោយមានកម្មវិធីនយោបាយយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលជាគោលមានផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សាខេត្តជាត្រីវិស័យ ក្នុងរយៈកាល៥ឆ្នាំចុងក្រោយនេះរដ្ឋបាលខេត្តឧត្តរមានជ័យបានសម្រេចបាននូវសមិទ្ធផលការងារជាច្រើនគួរជាទីមោទនៈ ឆ្លើយតបតាមសំណូមពរ និងតម្រូវការរបស់បងប្អូនប្រជាពលរដ្ឋនៅមូលដ្ឋានជាក់ស្តែង រួមមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធជាអាទិភាពដូចជាការកសាងប្រព័ន្ធគមនាគមន៍ ប្រព័ន្ធធារាសាស្រ្ត ការកែលម្អសោភណ្ឌភាពបរិស្ថាន ការរៀបចំសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជាដើម ។ល។ ដែលខ្ញុំព្រះករុណា

ខ្ញុំបាទសូមលើកយកចំណុចសំខាន់ៗមួយចំនួននៃវឌ្ឍនភាពក្នុងរយៈកាល ៥ឆ្នាំចុងក្រោយនេះជូនអង្គសន្និសីទបានជ្រាប។

+អំពីស្ថានភាពភូមិសាស្ត្រ ៖

ខេត្តឧត្តរមានជ័យ គឺជាខេត្តចុងក្រោយគេបង្អស់ក្នុងទូទាំងប្រទេសដែលបានសម្រេចធ្វើសមាហរណកម្មបញ្ចប់សង្គ្រាមស៊ីវិលរ៉ាំរ៉ៃនាថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៩៨ ក្រោមយុទ្ធសាស្ត្រនយោបាយ "ឈ្នះ-ឈ្នះ" របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី ដោយបានបញ្ចប់សង្គ្រាមផ្ទៃក្នុងទាំងស្រុងចេញពីប្រទេសកម្ពុជា និងត្រូវបានបង្កើតឡើងចំនួន ០៣លើក (កាលមុនជាអនុខេត្តសៀមរាប-ឧត្តរមានជ័យ) ក្នុងនោះលើកទី១ ដោយព្រះរាជក្រមលេខ ១៩៤ ប.រ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ១៩៦៤, លើកទី២ ដោយព្រះរាជក្រមលេខ ២៨២ ប.រ ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ១៩៦៦ និងបង្កើតលើកទី៣ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០១៩៥/០៧ ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ១៩៩៥ និងត្រូវបានធ្វើពិធីប្រកាសនៅថ្ងៃទី ២៧ ខែមេសា ឆ្នាំ១៩៩៩ ក្រោមអធិបតីភាពសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ មានឧត្តរមានជ័យភូមិសាស្ត្រស្ថិតនៅភាគឧត្តរនៃប្រទេស មានចម្ងាយ ៤៦៩គីឡូម៉ែត្រពីរាជធានីភ្នំពេញធ្វើដំណើរតាមផ្លូវជាតិលេខ៥ ឆ្លងកាត់ខេត្តចំនួន៦គឺខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ និងមានចម្ងាយ ៤៤៧គីឡូម៉ែត្រពីរាជធានីភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ ឆ្លងកាត់ខេត្តចំនួន៤គឺ ខេត្តកណ្តាល កំពង់ចាម កំពង់ធំ និងខេត្តសៀមរាប កាត់តាមស្រុកក្រឡាញ់ ឆ្ពោះមកកាន់ទីរួមខេត្តឧត្តរមានជ័យ ដែលមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹងខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងជាប់ជាមួយខេត្តចំនួន ៣របស់ថៃ គឺមានខេត្តសុរិន្ទ ខេត្តបុរីរ៉ាំ និងខេត្តស៊ីសាកេត មានប្រវែងសរុប ២២៤គីឡូម៉ែត្រ។

ខេត្តមានផ្ទៃដីសរុប ៦ ៨៤០,៩១គីឡូម៉ែត្រការ៉េ ចែកជា ០៥ស្រុក-ក្រុង មាន២៤ឃុំ-សង្កាត់ ស្មើនឹង ៣០៨ភូមិ និងមានប្រជាពលរដ្ឋសរុបចំនួន ២៦៤.៩៦៩នាក់ (ស្រី ១៣០.៩៨៥នាក់) ស្មើនឹង ៦៤.៦៥៦គ្រួសារ ក្នុងនោះបងប្អូនប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរកសិកម្ម ផ្តោតសំខាន់លើដំណាំស្រូវ ដំឡូងមី ចេក ស្វាយចន្ទី ស្វាយកែវរមៀត ពោត សណ្តែក និងអនុផលផ្សេងៗទៀត ដែលជាមុខរបរមួយធ្វើឲ្យប្រជាពលរដ្ឋមានជីវភាពកាន់តែល្អប្រសើរឡើង តាមរយៈការនាំចេញផលិតផលទៅកាន់ទីផ្សារក្នុងស្រុក ក៏ដូចជាទីផ្សារក្រៅប្រទេស។

ខេត្តមានច្រកទ្វារព្រំដែនអន្តរជាតិចំនួន ០៣ គឺច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ស្ថិតនៅក្នុងក្រុងសំរោង,ច្រកទ្វារព្រំដែនអន្តរជាតិជាំ ស្ថិតនៅក្នុងស្រុកអន្លង់វែង និងច្រកទ្វារព្រំដែន

អន្តរជាតិជប់គគីរ ស្ថិតនៅក្នុងបន្ទាយអំពិល ដែលភាគច្រើនបម្រើឲ្យគោលដៅសុមាលភាព និងទេសចរណ៍ច្រើនជាងគោលដៅសេដ្ឋកិច្ច។

សេដ្ឋកិច្ចរបស់ខេត្តពឹងផ្អែកលើវិស័យសំខាន់ៗចំនួនបី រួមមានវិស័យកសិកម្ម (ផ្តោតលើដំណាំកៅស៊ូ, ស្រូវ, ចេក, ស្វាយចន្ទី, ស្វាយកែវរមៀត និងដំឡូងមី ។ល។), វិស័យរ៉ែ (ផ្តោតលើរ៉ែមាស រ៉ែត្បូង សំណារ និងរ៉ែធ្យូងថ្ម) និងវិស័យទេសចរណ៍ (ផ្តោតលើទេសចរណ៍ធម្មជាតិ, ទេសចរណ៍វប្បធម៌ និងតំបន់ប្រវត្តិសាស្ត្រចំនួន ១៤ ដែលជាកេរ្តិ៍ដំណែលដែលបន្សល់ទុកដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ)។

បើរំលឹកពីអតីតកាល ឧត្តរមានជ័យជាតំបន់ដែលទទួលរងភាពខ្ទេចខ្ទាំដោយសារសង្គ្រាម បច្ចុប្បន្នក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចតេជោ **ហ៊ុន សែន** ខេត្តឧត្តរមានជ័យមានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពានខ្វែងខ្វាត់តភ្ជាប់ពីទីរួមខេត្តទៅកាន់តំបន់ព្រំដែនទៅកាន់បណ្តាក្រុង-ស្រុក ឃុំ-សង្កាត់ និងបានភ្ជាប់ទៅនឹងបណ្តាខេត្តផ្សេងៗទៀតដូចជាខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តព្រះវិហារជាដើម រីឯហេដ្ឋារចនាសម្ព័ន្ធរូបវន្តសង្គមក៏មានការរីកចម្រើន ដុះដាលគួរឲ្យកត់សម្គាល់ ដែលហាក់ផ្ទុយគ្នាយ៉ាងខ្លាំងបើធៀបនឹងអតីតកាលដែលខេត្តឧត្តរមានជ័យប្រៀបបីដូចជាកោះលើដីគោក។បច្ចុប្បន្ន ការដឹកជញ្ជូនផលិតផល ការសង្គ្រោះបន្ទាន់ពេលមានជំងឺគ្រោះអាសន្នផ្សេងៗលែងជាបញ្ហាប្រឈមសម្រាប់ប្រជាពលរដ្ឋខេត្តឧត្តរមានជ័យដូចពេលមុនៗទៀតហើយ ពិសេសខេត្តបានអភិវឌ្ឍកែប្រែមុខមាត់ជាបន្តបន្ទាប់ទៅតាមផែនការអភិវឌ្ឍរបស់ខេត្ត ដូចជាការកែប្រែហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍ពីផ្លូវដីស-ផ្លូវក្រាលគ្រួសក្រហមទៅជាផ្លូវកៅស៊ូ-ផ្លូវបេតុង, ការតភ្ជាប់បណ្តាញផ្លូវទៅកាន់បណ្តាឃុំនានា, ការកែលម្អតភ្ជាប់បណ្តាញលូមេក្នុងទីរួមខេត្ត, ការកែលម្អសោភណ្ឌភាពទីប្រជុំជន, ការពង្រីកការតភ្ជាប់បណ្តាញអគ្គិសនី ទឹកស្អាតជូនបងប្អូនប្រជាពលរដ្ឋទូទាំង ៥ក្រុង-ស្រុក, ការពង្រឹង ពង្រីក និងលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធផ្នែកអប់រំ សុខាភិបាល សាសនា កីឡា, លើកកម្ពស់វិស័យកសិកម្ម និងកសិឧស្សាហកម្មដោយគៀងគរក្រុមហ៊ុនវិនិយោគ អង្គការ និងដៃគូរអភិវឌ្ឍន៍នានាមកវិនិយោគក្នុងខេត្តលើដំណាំកៅស៊ូ ស្វាយ ដំណាំស្រូវ ស្វាយចន្ទី ចេក និងដំឡូងមីជាដើម។ល។ ក៏ដូចជាសហគ្រាសធនតូច-មធ្យម-ធំ ដែលរួមចំណែកជួយស្វែងរកការងារជូនប្រជាពលរដ្ឋ កាត់បន្ថយចំណាកស្រុក និងលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ ព្រមទាំងលើកកម្ពស់ខឿនការពារជាតិ ពង្រឹងទំនាក់ទំនងជាមួយប្រទេសជិតខាងបានល្អ ពិសេសការអភិវឌ្ឍតាមតំបន់ព្រំដែនតាមរយៈការពង្រីក និងវិនិយោគនៅតំបន់ច្រក ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដែលនេះសរបញ្ជាក់ឲ្យឃើញពីការរីកចម្រើនផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់ខេត្ត។

+អំពីការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ៖

តម្លៃសន្តិភាព និងការអភិវឌ្ឍនៅកម្ពុជាក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា គឺបានប្រកាន់ខ្ជាប់ឥតប្រែប្រួលនូវគោលបំណង និងឧត្តមគតិរបស់ខ្លួនដែលផ្សារភ្ជាប់ទៅនឹងគោលការណ៍ប្រជាធិបតេយ្យ ទោះបីត្រូវឆ្លងកាត់ការលំបាក និងបញ្ហាស្មុគ្រស្មាញជាច្រើនយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជាដែលកើតចេញពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ គឺស្ថិតនៅរួមសុខរួមទុក្ខជាមួយប្រជាជនជានិច្ច និងបានធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីផលប្រយោជន៍ជាតិ និងប្រជាជនគ្រប់ដំណាក់កាល។

សន្តិភាពដែលរកបានដោយលំបាក សន្តិសុខ ស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដោយនិរន្តរភាពកំពុងស្ថិតក្រោមការគំរាមកំហែង ដែលកំពុងកើតមានឡើងដោយសារការលាបពណ៌រូបភាពអវិជ្ជមាននៃស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា ដោយក្រុមជនអគតិមួយចំនួន និងបក្ខពួកទៅលើរាជរដ្ឋាភិបាលកម្ពុជាដែលបានចាត់វិធានការស្របច្បាប់ ដើម្បីការពារអធិបតេយ្យភាពរបស់ប្រទេស និងបានឆ្លើយតបទៅនឹងការប៉ុនប៉ងដែលអាចធ្វើឲ្យកម្ពុជាធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលម្តងទៀត សម្រាប់ខេត្តឧត្តរមានជ័យផ្ទាល់ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ និងក្រោមការចង្អុលបង្ហាញផ្ទាល់ពី សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើការងារសន្តិសុខយើងរក្សាបាននូវសុខសុវត្ថិភាពជូនប្រជាពលរដ្ឋលើការបង្ក្រាបនូវបទល្មើសនានាបានទាន់ពេលវេលា ការក្តាប់ និងទប់ស្កាត់នូវចេតនា និងឧបាយកលអាក្រក់របស់ពួកក្រុមអគតិដែលមានចេតនាបំផ្លាញសុខសន្តិភាព តាមរយៈការអនុវត្តច្បាប់ ការចុះអន្តរាគមន៍ពេលមានគ្រោះអាសន្នកើតឡើង ក្រោមរូបភាពនៃការប្រើប្រាស់យន្តការវិធានការសរុប មធ្យោបាយសរុប និងកម្លាំងសរុប ដោយមានគណៈបញ្ជាការរដ្ឋបាលឯកភាពខេត្ត ក្រុង ស្រុកជារចនាសម្ព័ន្ធចាត់តាំង ដឹកនាំ បញ្ជាយ៉ាងរឹងមាំ ដោយការពារបានយ៉ាងរឹងមាំនូវបូរណភាពទឹកដី និងកិច្ចសហប្រតិបត្តិការល្អជាមួយបណ្តាខេត្តរបស់ប្រទេសជិតខាង ពិសេសជាមួយបណ្តាកងឯកភាព និងអង្គភាពកងទ័ពដែលកំពុងឈរជើងការពារបូរណភាពទឹកដីក្នុងមូលដ្ឋានខេត្ត បង្ហាញពីការផ្សារភ្ជាប់រវាងសមរភូមិមុខ និងសមរភូមិក្រោយបានយ៉ាងល្អប្រសើរនិងចំពោះការអនុវត្តគោលនយោបាយ"ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព" បានចលនាបងប្អូនប្រជាពលរដ្ឋឲ្យចូលរួមក្នុងកិច្ចការពារសន្តិសុខក្នុងមូលដ្ឋាន ដោយបានចងក្រងជាក្រុមប្រជាការពារ និងបែងចែកជាគោលដៅច្បាស់លាស់ធានាឱ្យបានប្រៀបឈ្នះលើបទល្មើសនានា និងធានាបានការបង្ក្រាបបាន ១០០%។

អ្វីជាមោទកភាពសម្រាប់ខេត្តផងដែរ ជាលទ្ធផលនៃចលនាប្រឡងប្រណាំង "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ក្នុងឆ្នាំ២០២២កន្លងមកនេះ ខេត្តឧត្តរមានជ័យ ក្នុងចំណោម ២៥

ឃុំ-សង្កាត់ យើងបានទទួលជ័យលាភីចំណាក់ថ្នាក់លេខ១ មានចំនួន ២៣ឃុំ-សង្កាត់ និងជ័យលាភីចំណាក់ថ្នាក់លេខ២ មានចំនួន ១ឃុំ។

ក្រោយពីរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមការងារចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានៅរាជធានី-ខេត្តរួចមក ក្រុមការងារថ្នាក់ជាតិរបស់ខេត្តឧត្តរមានជ័យក្រោមការដឹកនាំដោយផ្ទាល់ឯកឧត្តមនាយឧត្តមសេនីយ៍កិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស បាននឹងកំពុងអនុវត្តតួនាទីភារកិច្ចស្នូលរបស់ខ្លួនយ៉ាងសកម្ម តាមរយៈការចុះក្តាប់សភាពការណ៍ និងដោះស្រាយរាល់បញ្ហាប្រឈម និងសំណូមពរនៅមូលដ្ឋានដោយផ្ទាល់ មានភាពឆាប់រហ័ស និងចំគោលដៅចង់បានរបស់បងប្អូនប្រជាពលរដ្ឋតាមរយៈការចុះធ្វើវេទិកាសាធារណៈ និងការចុះជួបសួរសុខទុក្ខតាមខ្នងផ្ទះរបស់ក្រុមការងារថ្នាក់ជាតិ និងថ្នាក់ខេត្តយ៉ាងសកម្ម ។

លើការងារផ្តល់សេវាសាធារណៈ បន្ទាប់ពីសមាហរណកម្មការិយាល័យជំនាញនានាជុំវិញក្រុង-ស្រុកទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង-ស្រុក តាមរយៈកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រដ្ឋបាលក្រុង ស្រុកទាំងអស់ក្នុងខេត្តបានទទួលរចនាសម្ព័ន្ធថ្មីកាន់តែមានលក្ខណៈល្អប្រសើរ សម្រួលដល់ការងារផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋកាន់ឆាប់រហ័ស មានតម្លាភាព ប្រសិទ្ធភាព គណនេយ្យភាព និងការពេញចិត្តពេញថ្លើមពីអ្នកប្រើប្រាស់សេវា។ មិនត្រឹមតែប៉ុណ្ណោះ រដ្ឋបាលខេត្ត ក្រុង-ស្រុក ឃុំ-សង្កាត់ ក៏ទទួលបានការធ្វើប្រតិភូកម្មអំណាចលើវិស័យមួយចំនួនក្នុងការផ្តល់សេវារដ្ឋបាល តាមរយៈយន្តការច្រកចេញចូលតែមួយផងដែរ ដែលបានបង្វិតការបម្រើសេវាកាន់តែកៀកដល់មូលដ្ឋាន និងជាយន្តការជំរុញការបម្រើសេវាតម្រូវការ និងសេវាសំណូមពរជូនបងប្អូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងបានកាន់តែលឿន ដោយទទួលបានការសាទរ និងគាំទ្រពីសំណាក់បងប្អូនប្រជាពលរដ្ឋផ្ទាល់តែម្តង។

ចំពោះការសម្របសម្រួល ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការលើវិស័យដីធ្លី យើងបានបន្តដោះស្រាយនិងបង្រួមទំនាស់ឲ្យកាន់តែនៅរួមតូចក្រោមយុទ្ធសាស្ត្រ "ឈ្នះ-ឈ្នះ" (លើកលែងតែសំណុំរឿងដែលជាសមត្ថកិច្ចតុលាការ ដែលកំពុងត្រូវអនុវត្តតាមនីតិវិធីរបស់តុលាការ) ក្រោមយន្តការដោះស្រាយរបស់គណៈកម្មការសុរិយោដី, គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត និងក្រុមការងារដីរដ្ឋក្រុងស្រុក និងករណីខ្លះយើងបង្កើតក្រុមការងារដោះស្រាយចំពោះកិច្ចតែម្តង។

-សម្តេច ឯកឧត្តម លោកជំទាវជាទីគោរព!

-ភ្ញៀវកិត្តិយស បងប្អូនអ្នកសារព័ត៌មាន និងទូរទស្សនិកជនជាទីគោរពរាប់អាន!

+អំពីការងារកសិកម្ម ៖

ជាខេត្តមានអំណោយផលលើវិស័យកសិកម្ម លើការងារដីដាំដុះដំណាំស្រូវយើងសម្រេចបានលើផ្ទៃដីចំនួន ៩៥ ០០០ហិកតា ទទួលបានបរិមាណផល ២៦២ ៦៩០តោន ដោយមានអត្រាកំណើនជាមធ្យម ៨,១២%ក្នុងមួយឆ្នាំ ក្នុងនោះមានអតិរេកស្រូវ ១៦៩ ៣៨០តោន ក្នុងឆ្នាំ២០២២កន្លងមក ដែលមានអត្រាកំណើនជាមធ្យមនៃអតិរេកស្រូវមានចំនួន ១១,៣៥% ក្នុងមួយឆ្នាំ។

ក្រៅពីស្រូវជាដំណាំយុទ្ធសាស្ត្រ ដំណាំកសិ-ឧស្សាហកម្មផ្សេងទៀតក៏មានការកើនឡើងជាលំដាប់គួរឱ្យកត់សម្គាល់ផងដែរ ក្នុងនោះដំណាំដំឡូងមីសម្រេចបានលើផ្ទៃដី ៧០ ៨៦០ហិកតា កើនឡើងប្រមាណ ២១,០៦% ដោយទទួលបានបរិមាណផលសរុបចំនួន ១ ៩៣៣ ៥២២តោន, ដំណាំស្វាយចន្ទីសម្រេចបានលើផ្ទៃដី ១៨ ៣៨២ហិកតា កើនឡើងប្រមាណ ១០៥,៩០% ដោយទទួលបានបរិមាណផលសរុប ១៤ ៦០០តោន មានអត្រាកំណើនជាមធ្យម ២២,៥៩% ក្នុងមួយឆ្នាំ, ដំណាំស្វាយកែវរមៀតសម្រេចបានលើផ្ទៃដី ១៣ ៥១៥ ហិកតា កើនឡើងប្រមាណ ៧៤,២៩% ដោយទទួលបានបរិមាណផលសរុប ២៨៣ ២៥០ តោន មានអត្រាកំណើនជាមធ្យម ២៨,៩០% ក្នុងមួយឆ្នាំ, ដំណាំកៅស៊ូសម្រេចបានលើផ្ទៃដី ១៥ ១៥៣ហិកតា ដោយទទួលបានបរិមាណផលសរុប ៨ ៧៥០តោន មានអត្រាកំណើនជាមធ្យម ៣៦,៣៨%ក្នុងមួយឆ្នាំ។

ដោយឡែក ក្នុងការលើកកម្ពស់ក្នុងវិស័យកសិកម្មនេះ យើងបានរៀបចំចងក្រងជាបណ្តុំអាជីវកម្មដំណាំនានាដូចជាបណ្តុំដំឡូងមី ត្រសក់ផ្អែម ឪឡឹកលឿង ស្វាយកែវរមៀត បន្លែ និងស្រូវជាដើម ដែលបច្ចុប្បន្នកំពុងឈានមុខក្នុងការដាំដុះ និងផ្គត់ផ្គង់លើផលិតផល ឪឡឹកលឿង ឪឡឹកទឹកក្រូច និងត្រសក់ផ្អែម (មីឡុង) រួមនឹងចេកអំបូងលឿងដែលបានដាំដុះលើផ្ទៃដីសរុបប្រមាណ ៨ ០៩៦ហិកតាក្នុងទូទាំងខេត្ត និងកំពុងប្រមូលផលជាបន្តបន្ទាប់សម្រាប់ផ្គត់ផ្គតទីផ្សារក្នុងស្រុក ក៏ដូចជានាំចេញទៅក្រៅប្រទេស។

ក្នុងនោះផងដែរ យើងក៏បានរៀបចំ និងចងក្រងផលិតកម្មតាមកិច្ចសន្យាជាមួយក្រុមហ៊ុន និងឈ្មួញប្រមូលទិញក្នុងខេត្ត-ក្រៅខេត្ត ដើម្បីចុះកិច្ចសន្យាផ្ទាល់ក្នុងការប្រមូលទិញផលិតផលកសិកម្មក្នុងតម្លៃមួយសមរម្យដោយមានការឯកភាពគ្នារវាងអ្នកផលិត និងអ្នកប្រមូលទិញ។

ជាយន្តការគាំទ្រលើវិស័យកសិកម្មនេះ ប្រព័ន្ធធារាសាស្ត្រគឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការគាំទ្រវិស័យកសិកម្ម។ ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងធនធានទឹក និងឧត្តុនិយមជាសេនាធិការដ៏ប៉ិនប្រសប់ បានធ្វើឲ្យខេត្តឧត្តរមានជ័យទទួលបានប្រព័ន្ធធារាសាស្ត្រធំៗចំនួន២ គឺទំនប់ស្ទឹងស្រែងមួយ និងស្ទឹង

ស្រែងពីរ ដែលអាចស្តុកទឹកបានប្រមាណជាង ២១១លានម៉ែត្រគូប និងមានវិសាលភាពអាចគ្របដណ្តប់បានចំនួន ២ខេត្តផ្សេងទៀតគឺខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ហើយក្រៅពីប្រព័ន្ធធារាសាស្ត្រធំៗទាំងពីរ យើងក៏មានអាងស្តុកទឹក និងទំនប់ស្ទាក់ទឹកជាច្រើនត្រូវបានសាងសង់រាយប៉ាយតាមបណ្តាភូមិ ឃុំ ក្រុង ស្រុកនានានៅក្នុងខេត្តផងដែរ។

+អំពីការងារអប់រំ ៖

លើវិស័យអប់រំ ទោះបីខេត្តឧត្តរមានជ័យទទួលបានសន្តិភាពពេញលេញក្រោយបណ្តាខេត្តដទៃក៏ដោយ ប៉ុន្តែការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សត្រូវបានរាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ជាអទិភាពដោយបានសាងសង់សាលារៀន អគារសិក្សានៅគ្រប់ទីកន្លែងក្នុងខេត្ត ដោយក្នុងនោះយើងមានវិទ្យាល័យចំនួន ៩សាលា, អនុវិទ្យាល័យចំនួន ៣០សាលា, សាលាបឋមសិក្សាចំនួន ២១៩សាលា, សាលាបណ្តុះបណ្តាល-បច្ចេកទេសចំនួន ២ រួមនឹងការចូលរួមពីវិស័យឯកជនក្នុងការបណ្តុះបណ្តាលលើផ្នែកភាសា និងជំនាញវិជ្ជាជីវៈផងដែរ។

អ្វីដែលគួរជាទីមោទកៈសម្រាប់ខេត្តផងដែរ គឺក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ កាលពីឆ្នាំសិក្សា២០២១-២០២២កន្លងទៅ ខេត្តឧត្តរមានជ័យមានបេក្ខជនមកប្រឡងសរុប ១ ៦០៤នាក់ (ស្រី ៨៥១នាក់) បេក្ខជនដែលប្រឡងជាប់មានចំនួន ១ ២២១នាក់ (ស្រី ៦៨៣នាក់) ស្មើនឹង ៧៦,១២% (ស្រី ៨០,២៦%) ក្នុងនោះមាននិទ្ទេសទទួលបាននិទ្ទេស A ចំនួន ០៦នាក់ (ស្រី ០៥នាក់)។

ចំណុចនេះ ខ្ញុំសូមទាញការចាប់អារម្មណ៍ពីសំណាក់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រីផងដែរថា សម្រាប់ខេត្តឧត្តរមានជ័យយើងខ្ញុំដោយអនុវត្តតាមគោលនយោបាយលើកកម្ពស់សមភាពយេនឌ័ររបស់រាជរដ្ឋាភិបាល យើងមានស្ត្រីជាថ្នាក់ដឹកនាំក្នុងជួរក្រុមប្រឹក្សាខេត្ត ០៦នាក់, គណៈអភិបាលខេត្ត ០២រូប, ស្ត្រីជាអភិបាលរងក្រុង ស្រុក ០៥រូប, ស្ត្រីជាប្រធានមន្ទីរ ០៤រូប ស្ត្រីជាមេឃុំ ០១រូប, ស្ត្រីជាក្រុមប្រឹក្សាក្រុង ស្រុក ១២រូប និងស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ ៨៣រូប បន្ថែមពីលើស្ត្រីក្នុងរចនាសម្ព័ន្ធគ្រប់គ្រងដឹកនាំក្នុងមន្ទីរ អង្គភាព និងស្ថាប័ននានាផងដែរ។

-សម្តេច ឯកឧត្តម លោកជំទាវជាទីគោរព!

-ភ្ញៀវកិត្តិយស បងប្អូនអ្នកសារព័ត៌មាន និងទូរទស្សនិកជនជាទីគោរពរាប់អាន!

បន្ថែមពីលើការសិក្សាក្នុងប្រព័ន្ធ យើងនៅតែបន្តជំរុញការសិក្សាដល់សហគមន៍ដាច់ស្រយាល និងការអប់រំក្រៅប្រព័ន្ធ ជាមួយនឹងការអប់រំអនាម័យ ហានិភ័យគ្រឿងញៀន ជំរុញឲ្យមានការចូលរួមលេងកីឡា និងបានចូលរួមប្រកួតប្រជែងកីឡាជាមួយបណ្តាខេត្ត និងក្លឹបផ្សេងផងដែរ។

+អំពីការងារសុខាភិបាល ៖

ចំពោះការងារសុខាភិបាល ដោយមានការគិតគូរខ្ពស់ពីសុខមាលភាពរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលបានបង្កើនមន្ទីរពេទ្យ មណ្ឌលសុខភាពជាច្រើននៅទូទាំងប្រទេស និងបានពង្រីកការសាងសង់ទៅតាមតំបន់ដាច់ស្រយាលផងដែរ ដើម្បីបង្ខិតសេវាសុខភាពសាធារណៈឲ្យកាន់តែខិតជិតប្រជាពលរដ្ឋ ក្នុងនោះក្នុងទូទាំងខេត្តឧត្តរមានជ័យបច្ចុប្បន្ន យើងមានស្រុកប្រតិបត្តិសុខាភិបាលចំនួន ០២, មានមន្ទីរពេទ្យបង្អែក ០២កន្លែង, មណ្ឌលសុខភាពចំនួន ៣៧មណ្ឌល និងប៉ុស្តិ៍សុខភាព ០១កន្លែង។

លើចំណុចការងារសុខាភិបាលនេះ អនុញ្ញាតឱ្យខ្ញុំសូមលើកឡើងរំលឹកបន្តិចអំពីការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ របស់អាជ្ញាធរខេត្ត កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ និងវិរៈកងទ័ពអាវសរបស់យើង ៖

កន្លងមកទល់នឹងបច្ចុប្បន្ននេះ រដ្ឋបាលខេត្តក្នុងនាមគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត និងជាគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ខេត្ត ដោយមានការចូលរួមពីគ្រប់សមាសភាពពាក់ព័ន្ធទាំងអស់ យើងបានទ្រទ្រង់ស្ថានភាពការណ៍ប្រឈមចំពោះមុខបានយ៉ាងល្អប្រសើរ ដោយប្រើប្រាស់យន្តការកម្លាំងសរុប មធ្យោបាយសរុប និងវិធានការសរុប ដើម្បីកាត់ផ្តាច់ខ្សែចម្លងនៅក្នុងសហគមន៍ប្រកបដោយសក្តិសិទ្ធិភាព។

គិតចាប់ពីថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២០ដែលជាដំណាក់កាលប្រឈមខ្លាំងជាសកលនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ប្រជាពលរដ្ឋ និងពលករឆ្លងដែនពីប្រទេសថៃមកតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ និងតាមច្រកទ្វារព្រំដែនអន្តរជាតិជាំមានចំនួន ១៥១ ១០២ នាក់។

មណ្ឌលចត្តាឡីស័កសរុបទូទាំងខេត្តមានចំនួន ២០ទីតាំង ក្នុងនោះស្ថិតនៅក្រុងសំរោងចំនួន ០៥ទីតាំង, ស្រុកបន្ទាយអំពិលចំនួន ០១ទីតាំង, ស្រុកចុងកាល់ចំនួន ០៤ទីតាំង, ស្រុកអន្លង់វែងចំនួន ០៥ទីតាំង និងស្រុកត្រពាំងប្រាសាទចំនួន ០៥ទីតាំង ដែលចំនួននេះមិនគ្រប់នឹងចំនួនប្រជាពលករដែលបានចូលមកយ៉ាងគំហុកនាពេលនោះទេ រហូតត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័កក្នុងខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិនទទួលរ៉ាប់រងជាបន្ត។

ចំពោះមណ្ឌលព្យាបាលសរុបទូទាំងខេត្តមានចំនួន ១៣ទីតាំង ក្នុងនោះស្ថិតនៅក្រុងសំរោងចំនួន ០៦ទីតាំង, ស្រុកបន្ទាយអំពិលចំនួន ០២ទីតាំង, ស្រុកអន្លង់វែងចំនួន ០៣ទីតាំង និងស្រុកត្រពាំងប្រាសាទចំនួន ០២ទីតាំង។

ខេត្តឧត្តរមានជ័យរកឃើញអ្នកជំងឺកូវីដ-១៩ សរុបចំនួន ១០.៩៦០នាក់ (ទាំងករណីនាំចូលពីបរទេស និងករណីសហគមន៍) ក្នុងនោះបានសម្រាកព្យាបាលជាសះស្បើយចំនួន ១០.៩០៤នាក់, ស្លាប់ ៥៦នាក់ និងកំពុងសម្រាកព្យាបាល "ពុំមាន"។

ចំពោះការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងចំណោមប្រជាពលរដ្ឋដែលមានអាយុចាប់ពី ៣ឆ្នាំឡើងសរុប ២៤៤.៨៤២នាក់ យើងចាក់ដូសមូលដ្ឋានបានចំនួន ២៣៣.៧៥៦នាក់ ស្មើនឹង ៩៥,៤៧% និងកំពុងបន្តចាក់ដូសទី៣ ទី៤ ទី៥ និងទី៦តាមវេនជាបន្តបន្ទាប់។

អនុញ្ញាតឱ្យខ្ញុំសូមយកឱកាសនេះផងដែរ សូមគោរពថ្លែងអំណរគុណចំពោះសម្តេចប្រមុខរាជរដ្ឋាភិបាល ចំពោះថ្នាក់ដឹកនាំក្រសួង ស្ថាប័នដែលពាក់ព័ន្ធដែលបានគិតគូរ និងផ្តល់អទិភាពខ្ពស់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ទាំងក្របខណ្ឌគោលនយោបាយ ច្បាប់ ស្មារតី និងសម្ភារ បរិក្ខា រួមនឹងថវិកាប្រតិបត្តិការ និងក៏មិនភ្លេចថ្លែងអំណរគុណចំពោះវិរៈកងទ័ពអាវស មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ រួមនឹងកងកម្លាំងទាំងបីប្រភេទដែលបានលះបង់កម្លាំងកាយ ចិត្តក្នុងភាពទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌ខ្ពស់ ដោយមិនបានយកសេចក្តីសុខផ្ទាល់ខ្លួន និងក្រុមគ្រួសារខ្លួនជាធំជាងសុខមាលភាពជារួមរបស់ប្រជាពលរដ្ឋ និងសូមអរគុណគ្រប់សមាសភាគពាក់ព័ន្ធទាំងអស់ ទាំងវិស័យឯកជន និងដៃគូរអភិវឌ្ឍន៍នានាដែលបានរួមសហការណ៍ជាមួយអាជ្ញាធរយ៉ាងសស្រាក់សស្រាំបំផុត ក្នុងការពួតដៃគ្នាប្រយុទ្ធប្រឆាំងយ៉ាងអង់អាចក្លាហានជាមួយសង្គ្រាមមេរោគមួយនេះក្នុងអំឡុងពេលនោះ និងសូមបន្តអំពាវនាវបងប្អូនប្រជា-ពលរដ្ឋទាំងអស់ឱ្យមកទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងដូសមូលដ្ឋានឱ្យបានពេញលេញ និងបន្តចាក់តាមវេនកំណត់ជាបន្តបន្ទាប់ ព្រោះយើងទាំងអស់គ្នាដឹងហើយថា មានតែវ៉ាក់សាំងកូវីដ-១៩ទេដែលអាចជួយបង្ការ ការពារយើងពីការឆ្លងវិវត្តន៍ទៅរកភាពធ្ងន់ធ្ងរ និងស្លាប់បាន។

+អំពីការងារថាមពល ៖

ក្នុងទូទាំងខេត្ត មានក្រុមហ៊ុន និងសេវាករអគ្គិសនីចំនួន ១០ (ក្រុមហ៊ុន០៤ និងសេវាករ០៦) កំពុងផ្គត់ផ្គង់បណ្តាញអគ្គិសនីក្នុងខេត្ត ក្នុងនោះក្នុងចំណោម ៣០៨ភូមិ យើងនៅសល់តែ ៣២ភូមិប៉ុណ្ណោះដែលមិនទាន់មានបណ្តាញអគ្គិសនីប្រើប្រាស់ ជារួមក្នុងចំណោមប្រជាពលរដ្ឋ ៦៤ ៦៥៦គ្រួសារយើងមាន ៣៣ ០៩៣គ្រួសារ ស្មើនឹង ៩០,៩៧% មានមានអគ្គិសនីប្រើប្រាស់ ហើយចំនួនដែលនៅសល់ តាមការរំពឹងទុកនឹងមានអគ្គិសនីប្រើប្រាស់ទាំងអស់ក្នុងអំឡុងខែមិថុនាខាងមុខ ដោយបច្ចុប្បន្នក្រុមការងារកំពុងធ្វើការពង្រីកការតភ្ជាប់បណ្តាញអគ្គិសនីបន្ថែមទៀតដល់គ្រប់មូលដ្ឋានភូមិឃុំជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាល។

ចំណុចកត់សម្គាល់ផងដែរ យើងមានរោងចក្រអគ្គិសនីដើរដោយថាមពលថ្មុងថ្មមួយកន្លែងផងដែរស្ថិតក្នុងស្រុកត្រពាំងប្រាសាទ ដោយបានសាងសង់ខ្សែបញ្ជូនអគ្គិសនីពីខេត្តឧត្តរមានជ័យទៅកាន់អនុស្ថានីយ៍ខាងកើតសៀមរាបរួចរាល់ និងគ្រោងដំណើរការក្នុងពេលដ៏ឆាប់ខាងមុខផងដែរ។

+អំពីការងារទឹកស្អាត ៖

លើការងារទឹកស្អាត យើងក្រុមហ៊ុនទឹកស្អាតឯកជនចំនួន ០៥ប្រតិបត្តិករ គ្រប់ដណ្តប់ការផ្គត់ផ្គង់ទឹកស្អាតបាន ៣៩ភូមិលើ ៣០៨ភូមិ ដោយមានប្រជាពលរដ្ឋទទួលផលប្រមាណ ២៧ ៥៣៦នាក់ និងកំពុងបង្កើនការផ្គត់ផ្គង់បន្ថែមជាបន្តបន្ទាប់។

+អំពីការងារសង្គមកិច្ច ៖

ការងារសំខាន់មួយដែលជាគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺការលើកកម្ពស់ការរស់នៅក្នុងសង្គម ដោយគិតត្រឹមថ្ងៃទី ២០ ខែមីនា ឆ្នាំ២០២៣នេះ ស្ត្រីមានផ្ទៃពោះ និងកុមារសរុបចំនួន ៤ ១៥៥នាក់ ទទួលបានការឧបត្ថម្ភសាច់ប្រាក់ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ មានទឹកប្រាក់សរុប ២.០២១.៩២០.០០០រៀល (ពីរពាន់ ម្ភៃមួយលាន ប្រាំបួនរយម្ភៃពាន់រៀលគត់) , កម្មវិធីផ្តល់សាច់ប្រាក់ជូនគ្រួសារក្រីក្រក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងជម្ងឺកូវីដ-១៩ មានចំនួន ១១.៦៩៧ គ្រួសារទឹកប្រាក់សរុប ៦៣.២៥០.៨៤០.០០០រៀល (ហុកសិបបីពាន់ ពីររយហាសិបលាន ប្រាំបីរយសែសិបពាន់រៀលគត់)។

បន្ថែមពីនេះ មានគ្រួសារចំនួន ៩០៣គ្រួសារបានទទួលផលពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងប្រជាពលរដ្ឋចំនួន ២ ៩០០គ្រួសារទទួលបានផលពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយទឹកជំនន់ សរុបទឹកប្រាក់ចំនួន ១.៣៦៦.២៧២.០០០រៀល (មួយពាន់ បីរយហុកសិបប្រាំមួយលាន ពីររយចិតសិបពីរពាន់រៀលគត់) និងក៏ជនមានពិការភាពក្រីក្រក្នុងសហគមន៍ចំនួន៧០០នាក់បានទទួលរបបគោលនយោបាយពីរាជរដ្ឋាភិបាលផងដែរ។

-សម្តេច ឯកឧត្តម លោកជំទាវជាទីគោរព!

-ភ្ញៀវកិត្តិយស បងប្អូនអ្នកសារព័ត៌មាន និងទូរទស្សនិកជនជាទីគោរពរាប់អាន!

+អំពីកិច្ចសហការណ៍ជាមួយអាជ្ញាធរ-សមត្ថកិច្ចនៃប្រទេសជិតខាង ៖

លើការងារកិច្ចសហការណ៍ជាមួយអាជ្ញាធរ-សមត្ថកិច្ចនៃប្រទេសជិតខាង យើងបានបន្ត និងបង្កើនកិច្ចសហប្រតិបត្តិការល្អរវាងអាជ្ញាធរខេត្តជាមួយបណ្តាប្រទេសជិតខាង គឺកើតចេញពី គោលនយោបាយដ៏ត្រឹមត្រូវ និងឈ្លាសវៃរបស់សម្តេចតេជោ **ហ៊ុន សែន** ដែលបាននាំមកនូវសន្តិភាព និងកិច្ចសប្រតិបត្តិជាមួយប្រទេសជិតខាង និងបណ្តាប្រទេសនានាលើសកលលោក។

រដ្ឋបាលខេត្តឧត្តរមានជ័យមានកិច្ចសហការផ្ទាល់ជាមួយបណ្ដាខេត្តទាំង ៣ របស់ប្រទេសថៃដែលជាខេត្តជាប់ព្រំដែនជាមួយគ្នារួមមានបុរីរ៉ាំ សុរិន្ទ និងស៊ីសាកេត ដោយបានចុះអនុស្សារណៈនៃការយោគយល់គ្នាលើគ្រប់វិស័យ ដែលឆ្លុះបញ្ចាំងលើការលើកកម្ពស់រក្សាសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខសណ្ដាប់ធ្នាប់តាមបណ្ដោយព្រំដែន ការទប់ស្កាត់បង្ក្រាបឧក្រិដ្ឋឆ្លងដែន ទប់ស្កាត់ការជួញដូរមនុស្ស និងគ្រឿងញៀនផងដែរ ព្រមទាំងរួមគ្នាពង្រឹងចំណងសាមគ្គីភាពមិត្តភាព និងកិច្ចសហការល្អលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចរវាងខេត្តទាំងពីរថែមទៀតផង សំដៅលើកកម្ពស់ការខិតខំរួមចំណែកជាមួយរាជរដ្ឋាភិបាល ធ្វើយ៉ាងណាប្រែក្លាយតំបន់ព្រំដែនទៅជាតំបន់ដែលមានការអភិវឌ្ឍប្រកបដោយសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការល្អ និងប្រកបដោយចីរភាព ដោយឈរលើគោលការណ៍អធិបតេយ្យភាព តម្កល់ផលប្រយោជន៍ជាតិជាធំ ស្របទៅតាមខ្លឹមសារជាសារវ័នដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ សន្ធិសញ្ញា កិច្ចព្រមព្រៀង និងសេចក្ដីថ្លែងការណ៍រួមដែលរដ្ឋាភិបាលប្រទេសទាំងពីរ កម្ពុជា-ថៃ បានឯកភាពគ្នានាពេលកន្លងមក ដើម្បីពង្រឹងពង្រីកចំណងកិច្ចសហប្រតិបត្តិការទ្វេភាគីតាមស្មារតី "ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ស្ថិរភាពយូរអង្វែង"។

ក្រៅពីនេះតាមរយៈកិច្ចប្រជុំ យើងតែងលើកជាសំណូមពរដល់ភាគីថៃចំពោះបញ្ហាការឆ្លងដែនខុសច្បាប់របស់ប្រជាពលរដ្ឋ ឬការបង្ក្រាបបទល្មើសនានា ស្នើកុំឲ្យមានការធ្វើទារុណកម្ម ឬបាញ់សម្លាប់ សូមអនុវត្តតាមច្បាប់ និងផ្អែកលើគោលការណ៍មនុស្សធម៌។

+អំពីការងារដែលជាអទិភាពដែលរដ្ឋបាលខេត្តកំពុងអនុវត្ត ៖

ចំពោះការងារដែលជាអាទិភាពដែលរដ្ឋបាលខេត្តកំពុងអនុវត្ត គឺបន្តពង្រឹងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ, ការខិតខំប្រឹងប្រែងកែលម្អ និងលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋតាមរយៈការបម្រើសេវាសាធារណៈ ទាំងសេវាតម្រូវការ និងសេវាសំណូមពររបស់បងប្អូនប្រជាពលរដ្ឋ ពិសេសលើសេវាសុខាភិបាលដើម្បីកាត់បន្ថយអត្រាមរណភាពមាតា និងទារក និងការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លង, ការប្រយុទ្ធប្រឆាំងគ្រឿងញៀន,ការពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក,ការស្វែងរកទីផ្សារលក់កសិផលផលិតផលស្របតាមយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋរបស់រាជរដ្ឋាភិបាល និងដើម្បីកាត់បន្ថយការចំណាកស្រុករបស់ប្រជាពលរដ្ឋ និងការងារគៀងគរកុមារដល់អាយុឲ្យចូលសិក្សា កាត់បន្ថយអត្រាបោះបង់ចោលការសិក្សា និងចំណុចសំខាន់មួយទៀតផងដែរគឺការកែលម្អហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ឲ្យកាន់តែប្រសើរថែមទៀត។

-សម្ដេច ឯកឧត្តម លោកជំទាវជាទីគោរព!

-ភ្ញៀវកិត្តិយស បងប្អូនអ្នកសារព័ត៌មាន និងទូរទស្សនិកជនជាទីគោរពរាប់អាន!

លទ្ធផលដូចបានជម្រាបជូនខាងលើ គឺជាសមិទ្ធផលសម្រេចបានរបស់រដ្ឋបាលខេត្ត ក៏ដូចជាបណ្តាវិស័យជំនាញក្នុងខេត្ត ដែលក្នុងនោះនៅមានបញ្ហាសេសសល់ ក៏ដូចជាទិសដៅថ្មីៗដែលបានដាក់ចេញត្រូវអនុវត្តជាបន្ត ដែលជំនាញគ្រប់ជាន់ថ្នាក់បានប្តេជ្ញាចិត្តក្នុងការពុះពារ និងរួមគ្នាដោះស្រាយឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

ខាងលើនេះជាអ្វីដែលខ្ញុំបាទសូមសង្ខេបជូនដើម្បីបានជ្រាប ហើយក្នុងឱកាសនេះក៏មានឯកឧត្តម លោកជំទាវ លោក លោកស្រីជាប្រធានមន្ទីរ អង្គភាពជំនាញមួយចំនួនបានអញ្ជើញមកចូលរួមផងដែរ ដូចនេះក្នុងករណីមានចម្ងល់ សំណួរដែលចង់ស្នើឱ្យមានការបំភ្លឺលម្អិតបន្ថែមលើការងារជំនាញ ឯកឧត្តម លោកជំទាវ លោក លោកស្រីនឹងធ្វើការបំភ្លឺជូនជាបន្ថែមបាន ជាពិសេសខ្ញុំផ្ទាល់នឹងរង់ចាំបកស្រាយបំភ្លឺជូនរាល់សំណួរទាំងឡាយរបស់បងប្អូនអ្នកសារព័ត៌មានតែម្តង។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលដែលបានផ្តល់ឱកាសដល់រដ្ឋបាលខេត្តឧត្តរមានជ័យបានធ្វើសន្និសីទសារព័ត៌មាន ស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តឧត្តរមានជ័យ" នាពេលនេះ ដើម្បីបង្ហាញសមិទ្ធផលនានាដែលខេត្តឧត្តរមានជ័យសម្រេចបានកន្លងមក និងការអភិវឌ្ឍខេត្តជូនសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងទូរទស្សនិកជន។

មុននឹងបញ្ចប់ ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះក្នុងនាមមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រប់ប្រភេទ និងប្រជាពលរដ្ឋក្នុងខេត្តឧត្តរមានជ័យទាំងមូល សូមបញ្ជាក់ការប្តេជ្ញាចិត្តគាំទ្រ និងអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាអគ្គមគ្គុទេសន៍ដ៏ឆ្នើមបំផុត ដែលបាននាំមកជូនជាតិមាតុភូមិនូវសន្តិសុខ ស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនាពេលបច្ចុប្បន្ន ហើយយើងទាំងអស់គ្នាប្តេជ្ញា រួមគ្នារក្សាការពារសន្តិភាពនេះឲ្យបានជាដាច់ខាត "អរគុណសន្តិភាព និងសូមអរគុណ សម្តេចតេជោ ដែលបានដឹកនាំកម្ពុជាឲ្យមានសន្តិភាព" ។

សូមគោរពជូនពរ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងទូរទស្សនិកជន សូមសមប្រកបពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាត។

សូមអរព្រះគុណ និងសូមអរគុណ៕